*EXCERPTS FROM CAMBODIA'S 2019 LFS REPORT (p.4-8), NIS*

## 1.4 Concepts and Definitions

CLFS 2019 followed the new international standards adopted by the 19th International Conference of Labour Statisticians (19th ICLS) in 2013. The 19th ICLS introduced a new framework for labour market statistics, including statistics related to the work, employment, and labour underutilization.

The definition of “employment” used in the Cambodia Labour Force and Child Labour Survey 2012 covered almost all activities within the System of National Accounts (SNA) production boundary, including production for pay, profit or family gain and production for own final use. The new definition of employment, however, includes only work performed for others for pay or profit; production for own final use is no longer regarded as employment. Therefore, some of the data generated from CLFS 2019 may not be comparable to the data from the Cambodia Labour Force and Child Labour Survey 2012.

Below are the definitions of concepts as given at the 19th ICLS:

**“Working age population”** refers to all persons aged 15 years and above. It comprises persons who are in the labour force (employed or unemployed), as well as persons outside the labour force.

**“Employed person”** refers to all individuals of working age who, during a short reference period (i.e., one week) were engaged in any activity to produce goods or provide services in exchange for pay or to generate profit. They comprise employed persons “at work” (i.e., who worked in a job for at least one hour) and employed persons “not at work” due to temporary absence from a job, or to working-time arrangements (such as shift work, flexitime, and compensatory leave for overtime).

Persons in employment are:

(i) persons who work for pay or profit who are participating in training or skills-enhancement activities required by the job or for another job in the same economic unit (such persons are considered as employed and “at work,” in accordance with the international statistical standards on work time);

(ii) apprentices, interns, or trainees who work for pay in cash or in kind;

(iii) persons who work for pay or profit through employment promotion programs;

(iv) persons who work in their own economic units to produce goods intended mainly for sale or barter, even if part of the output is consumed by the household or family;

(v) persons with seasonal jobs during the off season, if they continue to perform some tasks and duties of the job, excluding, however, fulfilment of legal or administrative obligations (e.g., paying taxes), irrespective of receipt of remuneration;

(vi) persons who work for pay or profit payable to the household or family;

(a) in market units operated by a family member living in the same or in another household; or
(b) performing tasks or duties of an employee job held by a family member living in the same or in another household

(vii) regular members of the armed forces and persons on military or alternative civilian service who perform this work for pay in cash or in kind.

The CLFS classifies a person at work as employed when he or she has worked for at least one hour during the reference week.

**"Unemployed person"** refers to all persons of working age who were not employed during the reference week, but who carried out activities to seek employment during a specified recent period, and were currently available to take up employment given a job opportunity.

Persons in unemployment are:

(i) "not in employment" is assessed with respect to the short reference period for the measurement of employment;

(ii) to "seek employment" refers to any activity when carried out, during a specified recent period comprising the last four weeks or one month, for the purpose of finding a job or setting up a business or agricultural undertaking. This also includes part-time, informal, temporary, seasonal or casual employment, within the national territory or abroad. Examples of such activities are:

(a) arranging for financial resources, applying for permits, licenses;

(b) looking for land, premises, machinery, supplies, farming inputs;

(c) seeking the assistance of friends, relatives, or other types of intermediaries;

(d) registering with or contacting public or private employment services;

(e) applying to employers directly, checking at worksites, farms, factory gates, markets or other assembly places;

(f) placing or answering newspaper or online job advertisements;

(g) placing or updating résumés on professional or social networking sites online;

(iii) the point when the enterprise starts to exist should be used to distinguish between search activities aimed at setting up a business and the work activity itself, as evidenced by the enterprise's registration to operate or by when financial resources become available, the necessary infrastructure or materials are in place, or the first client or order is received, depending on the context;

(iv) "currently available" serves as a test of readiness to start a job in the present, assessed with respect to a short reference period comprising that used to measure employment:

(a) depending on national circumstances, the reference period may be extended to include a short subsequent period not exceeding two weeks in total, so as to ensure adequate coverage of unemployment situations among different population groups.

Included in unemployment are:

(i) future starters defined as persons "not in employment" and "currently available" who did not "seek employment", because they had already made arrangements to start a job within a short subsequent period, set according to the general length of waiting time for starting a new job in the national context but generally not greater than three months;

(ii) participants in skills training or retraining schemes within employment promotion programmes, who on that basis, were "not in employment", not "currently available" and did not "seek employment" because they had a job offer to start within a short subsequent period generally not greater than three months;

(iii) persons "not in employment" who carried out activities to migrate abroad in order to work for pay or profit, but who were still waiting for the opportunity to leave.

**"Labour force"** refers to all persons of working age who contribute or are available to contribute to the production of goods and services in the country, in order to get paid or to obtain a profit. They were either employed or unemployed during the reference week prior to the survey.

**"Outside the labour force"** refers to all persons of working age who were not employed or unemployed during the specified reference period because of:

(i) attendance at an educational institution as a student;

(ii) engagement in household duties, caring for family members, or in other activities as housewives;

(iii) retirement or old age;

(iv) other reasons, such as infirmity or disablement, which may be specified; or

(v) a belief that no jobs are available, a lack of desire to work, or not available to start work within a short period.

**"Status in employment"** refers to the type of explicit or implicit contract of employment between the person and other persons or organization. The status of an economically active individual with respect to his or her employment (i.e., whether he or she is an employer, own-account worker, employee, or unpaid family worker) is defined as follows:

**An employee** is a person who works for a public or private employer and receives remuneration in wages, salary, commission, tips, piece rates, or pay in kind. Employees are divided into:

- regular paid employees with fixed wage,
- casual paid employees,
- workers paid by piece rate or work performed, and
- paid nonfamily apprentices.

**An employer** is a person who, during the reference period, was working on his or her own-account or with one or more partners at a "self-employment job" with one or more employees engaged on a continuous basis.

**An own-account worker** is a person who, during the reference period, was working on their own-account with one or more partners at a "self-employment job," without any employees engaged on a continuous basis; but, possibly, with one or more contributing family workers or employees engaged on an occasional basis. It includes owner-cultivators, share croppers, and contract cultivators working for profit.

**A contributing family worker** is a person who works without pay in cash or in kind in an enterprise operated by a member of his or her household or by a family member.

**"Others"** includes members of a producers' cooperative, etc.

**The formal sector** comprises all workers in the government, state-owned enterprises, international organizations, and in foreign embassies; as well as in limited companies, trading partnerships, limited partnerships, and enterprises that are registered with the relevant authorities and/or keep a complete set of accounts for reporting to the national government, including an accurate balance sheet of assets, income, and expenditures.

**The informal sector** comprises all workers in enterprises that are not registered with the relevant authorities, and do not keep a complete set of accounts. It excludes households that produce exclusively for own final use, subsistence agriculture, the construction of own dwellings, etc.

**A household** comprises all workers in household unincorporated enterprises that produce goods and services exclusively or mainly for their own final use. It includes paid domestic workers employed by the household. Persons classified in International Standard Industrial Classification of All Economic Activities (ISIC) Revision 4 division 97, and International Standard Classification of Occupations 2008 (ISCO-08) group 63 are included here.

**Formal employment** includes persons who work in their own businesses in the formal sector or who are employees, apprentices, interns of an employer who makes contributions to a national pension fund, health, and/or unemployment insurance fund, or who provides paid annual leave and sick leave in cases of illness or injury.

**Informal employment** includes employers and own-account workers who are employed in their own informal sector enterprises; contributing family workers; and employees and paid apprentices or interns who do not have paid annual leave or sick leave benefits, and whose employers do not contribute to their social security. This population is derived in the report as a residual of the total number of persons employed and persons in formal employment.

**"Time-related underemployment"** refers to all persons in employment who, during a short reference period, wanted to work additional hours, but whose working time in all jobs was less than a specified hours threshold (40 hours in the case of Cambodia), and who were available to work additional hours given an opportunity for more paid work, where:

(i) "working time" refers to the hours actually worked or usually worked, depending on the measurement objective (short or long-term situations) and in accordance with the international statistical standards on the topic;

(ii) “additional hours” may be extra hours spent in the same job, in one or more additional jobs, or in one or more replacement jobs;

(iii) “specified hours threshold” is based on the boundary between full-time and part-time employment, on the median or modal values of the hours usually worked of all persons in employment, or on working-time norms as specified in the relevant legislation or national practice, and set for specific worker groups; and

(iv) “available to work additional hours” should be defined in reference to a short reference period that reflects the typical length of time required in the national context between leaving one job and starting another.

**“Potential labour force (entrants)”** refers to all persons of working age who, during the short reference period, were neither in employment nor in unemployment and:

(i) carried out activities to “seek employment”, were not “currently available” but would become available within a short subsequent period established in the light of national circumstances (i.e., unavailable jobseekers); or

(ii) did not carry out activities to “seek employment”, but wanted employment and were “currently available” (i.e., available potential jobseekers).

(ដកស្រង់ពីរបាយការណ៍អង្កេតកម្លាំងកម្ពុជា២០២៩ ទំព័រទី៤ដល់ទី៨)

## ១.៤ ទស្សនាទាន និងនិយមន័យ

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានអនុវត្តតាមស្តង់ដារអន្តរជាតិថ្មី ដែលបានអនុម័តដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣។ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ បានដាក់ចេញនូវក្របខ័ណ្ឌថ្មីមួយសម្រាប់ស្ថិតិទីផ្សារការងារ រួមមានស្ថិតិទាក់ទងនឹងការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

និយមន័យ "ភាពមានការងារធ្វើ" ដែលបានប្រើនៅក្នុងអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ឆ្នាំ២០១២ បានគ្របដណ្តប់លើសកម្មភាពស្ទើរតែទាំងអស់នៅក្នុងព្រំដែនផលិតកម្មនៃប្រព័ន្ធគណនេយ្យជាតិ រួមមានការផលិតសម្រាប់ប្រាក់ឈ្នួល ប្រាក់ចំណេញ ឬចំណេញរបស់គ្រួសារ និងការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយខ្លួនឯង។ និយមន័យថ្មីនៃភាពមានការងារធ្វើ ទោះជាយ៉ាងណាក៏ដោយ រួមបញ្ចូលតែការងារដែលបានធ្វើសម្រាប់អ្នកផ្សេងដើម្បីប្រាក់ឈ្នួល ឬចំណេញប៉ុណ្ណោះ ចំណែកឯការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយខ្លួនឯងមិនត្រូវបានប្រើ និងចាត់ទុកថាភាពមានការងារធ្វើទៀតឡើយ។ ដូច្នេះ ទិន្នន័យមួយចំនួនរបស់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ នឹងមិនអាចប្រៀបធៀបនឹងទិន្នន័យរបស់អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ឆ្នាំ២០១២ ឡើយ។

ខាងក្រោមនេះជានិយមន័យនៃទស្សនាទានដែលបានផ្តល់ដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩៖

**ប្រជាជនក្នុងអាយុធ្វើការ** សំដៅលើមនុស្សទាំងអស់អាយុ ១៥ ឆ្នាំឡើង។ ប្រជាជនក្នុងអាយុធ្វើការរួមមានអ្នកនៅក្នុងកម្លាំងពលកម្ម (ជាអ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ) ក៏ដូចជាអ្នកនៅក្រៅកម្លាំងពលកម្ម។

**អ្នកមានការងារធ្វើ** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោងខ្លី (ពោលគឺមួយសប្តាហ៍) បានចូលរួមក្នុងសកម្មភាពណាមួយ ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មប្តូរយកប្រាក់ឈ្នួល ឬដើម្បីរកចំណេញ។ ពួកគេរួមមានអ្នកធ្វើការ "នៅកន្លែងការងារ" (ពោលគឺអ្នកដែលបានធ្វើការយ៉ាងហោចណាស់មួយម៉ោង) និងអ្នកធ្វើការ "មិននៅកន្លែងការងារ" ដោយសា រតែអវត្តមានបណ្តោះអាសន្នពីការងារ ឬដោយសារការរៀបចំពេលវេលាធ្វើការ (ដូចជាការងារប្តូរវេន ការបញ្ចប់ការងារា មពេលវេលាខុសគ្នា និងការឈប់សម្រាកសងម៉ោងបន្ថែម)។

អ្នកមានការងារធ្វើ រួមមាន៖

(i) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ ដែលកំពុងចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬក្នុងសកម្មភាពបង្កើនជំនាញដែលទាមទារដោយការងារ ឬសម្រាប់ការងារផ្សេងទៀតនៅក្នុងអង្គភាពសេដ្ឋកិច្ចតែមួយ (អ្នកទាំងនេះត្រូវបានចាត់ទុកជាអ្នកធ្វើការ "នៅកន្លែងការងារ" ដោយអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីពេលវេលាធ្វើការ)

(ii) អ្នករៀនធ្វើការ អ្នកហាត់ការ ឬអ្នកហាត់រៀន ដែលធ្វើការដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់
(iii) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ តាមរយៈកម្មវិធីលើកកម្ពស់ការងារ
(iv) អ្នកធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចខ្លួនឯង ដើម្បីផលិតទំនិញក្នុងគោលបំណងចម្បងសម្រាប់លក់ ឬដោះដូរ ទោះបីផ្នែកខ្លះនៃផលិតផលត្រូវបានប្រើប្រាស់ដោយក្រុមគ្រួសារ ឬគ្រួសារក៏ដោយ
(v) អ្នកមានការងារតាមរដូវក្នុងពេលបិទរដូវ បើពួកគេនៅបន្តបំពេញភារកិច្ច និងកិច្ចការមួយចំនួននៃការងារ ដោយមិនរាប់បញ្ចូលការបំពេញកាតព្វកិច្ចផ្លូវច្បាប់ ឬរដ្ឋបាល (ឧទាហរណ៍ បង់ពន្ធ) និងមិនគិតការទទួលបានអត្ថប្រយោជន៍
(vi) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ ដែលត្រូវបង់ឲ្យក្រុមគ្រួសារ ឬគ្រួសារ
(ក) នៅក្នុងទីផ្សារប្រតិបត្តិការដោយសមាជិកគ្រួសាររស់នៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
(ខ) បំពេញភារកិច្ច ឬកិច្ចការជានិយោជិតរបស់សមាជិកគ្រួសារនៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
(vii) ជាសមាជិកទៀងទាត់នៃកងកម្លាំងប្រដាប់អាវុធ និងអ្នកមានមុខងារជាយោធា ឬជាស៊ីវិលជំនួស ដែលបំពេញការងារនេះដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។

អង្កេតកម្លាំងពលកម្មកម្ពុជាបានចាត់ថ្នាក់អ្នកនៅកន្លែងការងារជាអ្នកមានការងារធ្វើ កាលណាគាត់បានធ្វើការយ៉ាងហោចណាស់មួយម៉ោងក្នុងសប្តាហ៍យោង។

**អ្នកគ្មានការងារធ្វើ** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលមិនបានធ្វើការងារក្នុងរយៈពេលសប្តាហ៍យោង ប៉ុន្តែបានអនុវត្តសកម្មភាពស្វែងរកការងារធ្វើក្នុងរយៈពេលថ្មីៗជាក់លាក់មួយ និងបច្ចុប្បន្នអាចទទួលយកការងារធ្វើបាន នៅពេលផ្តល់ឱកាសការងារឲ្យ។

អ្នកគ្មានការងារធ្វើ រួមមានៈ
(i) "មិនធ្វើការងារ" ត្រូវបានវាយតម្លៃដោយយោងទៅលើរយៈពេលយោងខ្លី សម្រាប់ការវាស់វែងការងារ
(ii) "បានស្វែងរកការងារធ្វើ" សំដៅលើសកម្មភាពណាមួយដែលបានអនុវត្ត ក្នុងរយៈពេលថ្មីៗជាក់លាក់មួយ រួមមាន ៤ សប្តាហ៍ ឬមួយខែមុន សម្រាប់គោលបំណងរកការងារ ឬបង្កើតអាជីវកម្ម ឬធ្វើកសិកម្ម។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការងារក្រៅម៉ោង ការងារក្រៅប្រព័ន្ធ ការងារបណ្តោះអាសន្ន និងការងារតាមរដូវ ឬម្តងម្កាល ក្នុងប្រទេស ឬក្រៅប្រទេស។ ឧទាហរណ៍នៃសកម្មភាពទាំងនេះគឺៈ
(ក) ការរៀបចំធនធានហិរញ្ញវត្ថុ ដាក់ពាក្យសុំការអនុញ្ញាត អាជ្ញាប័ណ្ណ
(ខ) ស្វែងរកដី ទីក្នុងបរិវេណ ម៉ាស៊ីន សម្ភារៈផ្គត់ផ្គង់ ឧបករណ៍កសិកម្ម
(គ) ស្វែងរកជំនួយពីមិត្តភក្តិ សាច់ញាតិ ឬប្រភេទអន្តរការីផ្សេងទៀត
(ឃ) ចុះឈ្មោះជាមួយ ឬទាក់ទងសេវាកម្មការងារសាធារណៈ ឬឯកជន
(ង) ដាក់ពាក្យសុំដោយផ្ទាល់ដល់និយោជក ឆែកពិនិត្យកន្លែងធ្វើការ កសិដ្ឋាន ច្រកទ្វាររោងចក្រ ទីផ្សារ ឬកន្លែងជួបប្រជុំផ្សេងទៀត
(ច) ដាក់ពាក្យ ឬឆ្លើយតាមសារព័ត៌មាន ឬការផ្សាយពាណិជ្ជកម្មការងារតាមអនឡាញ
(ឆ) ដាក់ពាក្យ ឬធ្វើបច្ចុប្បន្នកម្មប្រវត្តិអំពីវិជ្ជាជីវៈ ឬគេហទំព័របណ្តាញសង្គមតាមអនឡាន
(iii) ចំណុចដែលសហគ្រាសចាប់ផ្តើមមានគួរតែត្រូវបានប្រើ ដើម្បីដឹងនូវភាពផ្សេងគ្នារវាងសកម្មភាពស្វែងរកក្នុងគោលដៅបង្កើតអាជីវកម្ម និងសកម្មភាពការងាររបស់ខ្លួនឯងផ្ទាល់ ដែលបង្ហាញភស្តុតាងតាមការចុះឈ្មោះសហគ្រាសដើម្បីប្រតិបត្តិការ ឬតាមនៅពេលមានធនធានហិរញ្ញវត្ថុ មានហេដ្ឋារចនាសម្ព័ន្ធ ឬសម្ភារៈចាំបាច់នៅនឹងកន្លែង ឬបានទទួលអតិថិជន ឬការបញ្ជាទិញដំបូង អាស្រ័យលើស្ថានភាពជាក់ស្តែង

(iv) "បច្ចុប្បន្នអាចធ្វើការបាន" ចង់ដឹងពីការត្រៀមខ្លួនជាស្រេច ដើម្បីចាប់ផ្តើមការងារក្នុងពេលបច្ចុប្បន្ន ដែលវាយតម្លៃដោយរយៈពេលយោងខ្លីមួយប្រើសម្រាប់វាស់វែងការងារ៖

(ក) អាស្រ័យលើកាលៈទេសៈប្រទេស រយៈពេលយោងអាចរាប់បញ្ចូលរយៈពេលបន្តបន្ទាប់ខ្លីមួយ មិនលើសពីរសប្តាហ៍គិតជាសរុប ដើម្បីធានាវិសាលភាពគ្រប់គ្រាន់នៃស្ថានភាពគ្មានការងារធ្វើក្នុងចំណោមក្រុមប្រជាជនខុសគ្នា។

រាប់បញ្ចូលក្នុងភាពគ្មានការងារធ្វើ៖

(i) អ្នកចាប់ផ្តើមនាពេលអនាគតបានកំណត់ជាមនុស្ស "មិនធ្វើការងារ" និង "បច្ចុប្បន្នអាចធ្វើការបាន" ដែលមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេបានរៀបចំរួចហើយ ដើម្បីចាប់ផ្តើមការងារក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ដោយកំណត់លើរយៈពេលរង់ចាំជាទូទៅសម្រាប់ការចាប់ផ្តើមការងារថ្មីនៅក្នុងបរិបទប្រទេស ប៉ុន្តែជាទូទៅមិនច្រើនជាងបីខែ

(ii) អ្នកចូលរួមក្នុងការបណ្តុះបណ្តាលជំនាញ ឬគម្រោងបណ្តុះបណ្តាលឡើងវិញក្នុងកម្មវិធីលើកកម្ពស់ការងារ ដោយផ្អែកលើមូលដ្ឋាន "មិនធ្វើការងារ" និងមិន "បច្ចុប្បន្នអាចធ្វើការបាន" និងមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេមានការងារដែលផ្តល់ឲ្យដែលត្រូវចាប់ផ្តើមក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ជាទូទៅមិនច្រើនជាងបីខែ

(iii) អ្នក "មិនធ្វើការងារ" ដែលបានអនុវត្តសកម្មភាពចំណាកស្រុកទៅបរទេស ដើម្បីធ្វើការយកប្រាក់ឈ្នួល ឬចំណេញ ប៉ុន្តែពួកគេនៅរង់ចាំឱកាសចាកចេញ។

**កម្លាំងពលកម្ម** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលចូលរួមចំណែក ឬអាចចូលរួមចំណែកក្នុងការផលិតទំនិញ និងសេវាកម្មនៅក្នុងប្រទេស ដើម្បីយកប្រាក់ឈ្នួល ឬទទួលបានចំណេញ។ ពួកគេអាចជាអ្នកមានការងារធ្វើ ឬគ្មានការងារធ្វើ ក្នុងរយៈពេលសប្តាហ៍យោងមុនអង្កេត។

**អ្នកនៅក្រៅកម្លាំងពលកម្ម** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលអត់ធ្វើការ ឬមិនធ្វើការងារក្នុងរយៈពេលយោងជាក់លាក់ ដោយសារ៖

(i) ជាប់រៀននៅគ្រឹះស្ថានសិក្សាជាសិស្ស

(ii) ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬក្នុងសកម្មភាពផ្សេងៗជាមេផ្ទះ

(iii) ចូលនិវត្តន៍ ឬចាស់ជរា

(iv) មូលហេតុផ្សេងទៀត ដូចជាភាពទន់ខ្សោយ ឬពិការភាព ដែលអាចបញ្ជាក់បាន ឬ

(v) ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនមានការចាប់ផ្តើមការងារក្នុងរយៈពេលខ្លី។

**ស្ថានភាពការងារ** សំដៅលើប្រភេទកិច្ចសន្យាការងារជាក់ស្តែង ឬមិនជាក់លាក់នៃការងាររវាងមនុស្ស និងមនុស្ស ឬអង្គការផ្សេងទៀត។ ស្ថានភាពរបស់បុគ្គលសកម្មសេដ្ឋកិច្ចត្រូវគោរពតាមការងាររបស់ខ្លួន (ពោលទោះបីគាត់ជានិយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និយោជិត ឬអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល) ត្រូវបានកំណត់ដូចខាងក្រោម៖

**និយោជិត** គឺជាមនុស្សម្នាក់ ដែលធ្វើការឲ្យនិយោជកសាធារណៈ ឬឯកជន ហើយទទួលសំណងជាប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃជើងសារ ប្រាក់ទឹកតែ ប្រាក់តាមអត្រាការងារ ឬឲ្យជារបស់។ និយោជិតត្រូវបានបែងចែកជា៖

- និយោជិតមានប្រាក់ឈ្នួលទៀងទាត់ ជាមួយប្រាក់ឈ្នួលថេរ
- និយោជិតមានប្រាក់ឈ្នួលមិនទៀងទាត់/បណ្តោះអាសន្ន
- អ្នកធ្វើការមានប្រាក់ឈ្នួលតាមអត្រាការងារ ឬតាមការងារដែលបានបំពេញ និង
- អ្នករៀនធ្វើការមានប្រាក់ឈ្នួលមិនមែនគ្រួសារ។

**និយោជក** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់គាត់ ឬជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ជាមួយនិយោជិតម្នាក់ ឬច្រើននាក់ចូលរួមការងារជាប្រចាំជាមូលដ្ឋាន។

**អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់ពួកគេជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ដោយគ្មាននិយោជិតណាមួយចូលរួមការងារជាប្រចាំ ប៉ុន្តែក៏អាចជាមួយអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួលម្នាក់ ឬច្រើននាក់ចូលរួមការងារម្តងម្កាលជាមូលដ្ឋានផងដែរ។ អ្នកធ្វើការប្រភេទនេះ រួមមានម្ចាស់អ្នកដាំដុះ អ្នកដាំដំណាំចែកគ្នា និងអ្នកដាំដុះកិច្ចសន្យាធ្វើការដើម្បីចំណេញ។

**អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល** គឺជាមនុស្សម្នាក់ដែលធ្វើការដោយគ្មានប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់ ក្នុងសហគ្រាសមួយដែលប្រតិបត្តិការដោយសមាជិកក្រុមគ្រួសាររបស់គាត់ ឬដោយសមាជិកគ្រួសារមួយ។

**ផ្សេងទៀត** រួមមានសមាជិកនៃសហករណ៍អ្នកផលិត ។ល។

**វិស័យក្នុងប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងរដ្ឋាភិបាល ឬសហគ្រាសរដ្ឋ ឬអង្គការអន្តរជាតិ និងក្នុងស្ថានទូតបរទេស ក៏ដូចជាក្រុមហ៊ុនមានដែនកំណត់ ភាពជាដៃគូពាណិជ្ជកម្ម ភាពជាដៃគូមានដែនកំណត់ និងសហគ្រាសបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និង/ឬ មានបញ្ជីគណនេយ្យពេញលេញសម្រាប់រាយការណ៍ទៅរដ្ឋាភិបាល រួមមានតារាងតុល្យភាពត្រឹមត្រូវមួយនៃទ្រព្យសម្បត្តិ ចំណូល និងចំណាយ។

**វិស័យក្រៅប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសដែលមិនបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និងគ្មានបញ្ជីគណនេយ្យពេញលេញ។ វិស័យក្រៅប្រព័ន្ធមិនរាប់បញ្ចូលគ្រួសារដែលផលិតសម្រាប់តែការប្រើប្រាស់ចុងក្រោយខ្លួនឯង កសិកម្មសម្រាប់ចិញ្ចឹមជីវិត ការសាងសង់លំនៅដ្ឋានខ្លួនឯង ។ល។

**គ្រួសារ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសគ្រួសារដែលផលិតទំនិញ និងសេវាកម្មសម្រាប់តែការប្រើប្រាស់ចុងក្រោយខ្លួនឯង។ គ្រួសារ រួមមានអ្នកធ្វើកិច្ចការផ្ទះមានប្រាក់ឈ្នួលជួលដោយគ្រួសារ។ បុគ្គលដែលបានចាត់ចូលក្នុងផ្នែក៩៧ នៃចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់៤ (ISIC) និងផ្នែក៦៣ នៃចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) ត្រូវបានរាប់បញ្ចូលក្នុងវិស័យនេះ។

**ការងារក្នុងប្រព័ន្ធ** រួមមានអ្នកដែលធ្វើការនៅក្នុងអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេក្នុងវិស័យក្នុងប្រព័ន្ធ ឬអ្នកធ្វើការជានិយោជិត អ្នករៀនធ្វើការ អ្នកហាត់ការរបស់និយោជកដែលចូលរួមវិភាគទានដល់របបសោធននិវត្តន៍ សុខភាព និង/ឬមូលនិធិធានារ៉ាប់រងភាពគ្មានការងារធ្វើ ឬផ្តល់ប្រាក់ឈ្នួលឈប់សម្រាកប្រចាំឆ្នាំ និងឈប់សម្រាកឈឺក្នុងករណីមានជំងឺ ឬរបួស។

**ការងារក្រៅប្រព័ន្ធ** រួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិតនិងអ្នករៀនធ្វើការនិងអ្នកហាត់ការដែលគ្មានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមវិភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។ ចំនួនមនុស្សក្នុងផ្នែកនេះ ជាផលសងរវាងចំនួនមនុស្សទាំងអស់ដែលបានធ្វើការ និងចំនួនមនុស្សក្នុងការងារក្នុងប្រព័ន្ធ។

**ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា** សំដៅលើមនុស្សទាំងអស់ក្នុងការងារ ដែលក្នុងរយៈពេលយោងខ្លី ចង់ធ្វើការម៉ោងបន្ថែម ដោយសារចំនួនម៉ោងធ្វើការក្នុងការងារទាំងអស់របស់គាត់តិចជាងកម្រិតម៉ោងដែលបានកំណត់ (៤០ ម៉ោង សម្រាប់កម្ពុជា) ហើយគាត់អាចធ្វើការម៉ោងបន្ថែមបានបើផ្តល់ឱកាសការងារមានប្រាក់ឈ្នួលបន្ថែមទៀត ដែល៖

(i) "ម៉ោងធ្វើការ" សំដៅលើចំនួនម៉ោងជាក់ស្តែងបានធ្វើការ ឬចំនួនម៉ោងធម្មតាបានធ្វើការ អាស្រ័យលើគោលដៅនៃការវាស់វែង (ស្ថានភាពរយៈពេលខ្លី ឬវែង) និងអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីប្រធានបទ

(ii) "ម៉ោងបន្ថែម" អាចជាម៉ោងលើសនៅក្នុងការងារតែមួយ នៅក្នុងមួយឬច្រើនការងារបន្ថែម ឬនៅក្នុងមួយឬច្រើនការងារជំនួស

(iii) "កម្រិតកំណត់ចំនួនម៉ោង" គឺផ្អែកលើព្រំដែនរវាងការងារម៉ោងពេញ និងម៉ោងក្រៅ លើតម្លៃមេដ្យាន ឬម៉ូតនៃចំនួនម៉ោងធ្វើការធម្មតារបស់អ្នកធ្វើការងារទាំងអស់ ឬលើបទដ្ឋានចំនួនម៉ោងធ្វើការដូចមានចែងក្នុងច្បាប់ពាក់ព័ន្ធ ឬការអនុវត្តថ្នាក់ជាតិ និងការកំណត់សម្រាប់ក្រុមអ្នកធ្វើការជាក់លាក់ និង

(iv) "អាចធ្វើការងារម៉ោងបន្ថែម" ត្រូវបានកំណត់ក្នុងរយៈពេលយោងខ្លីមួយ ដែលឆ្លុះបញ្ចាំងពីរយៈពេលតាមតម្រូវការនៅក្នុងបរិបទប្រទេសរវាងការចាកចេញពីការងារមួយ និងការចាប់ផ្តើមការងារផ្សេងទៀត។

**កម្លាំងពលកម្មសក្តានុពល (អ្នកចូលរួម)** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោងខ្លី មិនបានធ្វើការងារ ឬគ្មានការងារធ្វើ ហើយ៖

(i) ធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ហើយមិន "បច្ចុប្បន្នអាចធ្វើការបាន" ប៉ុន្តែនឹងអាចធ្វើបានក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ទៅតាមកាលៈទេសៈប្រទេស (ពោលគឺអ្នកស្វែងរកការងារតែមិនអាចធ្វើបាន) ឬ

(ii) មិនធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ប៉ុន្តែចង់ធ្វើការ និង "បច្ចុប្បន្នអាចធ្វើការបាន" (ពោលគឺអ្នកស្វែងរកការងារមានសក្តានុពលដែលអាចធ្វើបាន)។